# និន្នាការសេដ្ឋកិច្ចសង្គម

# Socio-Economic Trends

**ខែមករា - កុម្ភៈ ឆ្នាំ២០១៧**

**January - February 2017**

## មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប / Executive summary** | **២** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends** | **៦** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index | ៦ |
| ១.២. វិស័យហិរញ្ញវត្ថុ / Finance | ៧ |
| ១.៣. វិស័យពាណិជ្ជកម្ម / Trade | ៩ |
| ១.៤. ការអនុវត្តថវិកា / Budget execution | ១០ |
| ១.៥. វិស័យវិនិយោគឯកជន / Private investment | ១១ |
| ១.៦. វិស័យទេសចរណ៍ / Tourism | ១១ |
| ១.៧. វិស័យសំណង់ / Construction | ១២ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ / International commodity prices** | **១២** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១២ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១៣ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១៣ |
| **៣. ឧបសម្ព័ន្ធ** | **១៤** |

## ខ្លឹមសារសង្ខេប

១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែមករា ឆ្នាំ២០១៧ បានកើនឡើង ០,៣% ធៀបនឹងខែមុន និងបានកើនឡើង ៤,៤% ធៀបនឹង១២ខែមុន។

សន្ទស្សន៍ថ្លៃនៃក្រុមទំនិញដែលកើនឡើងគួរកត់សម្គាល់ធៀបនឹងខែធ្នូកន្លងទៅមានដូចជា សន្ទស្សន៍ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រវឹង បានកើនឡើង ០,៣% ដោយសារកំណើនថ្លៃសាច់ជ្រូក សាច់គោ សាច់មាន់ ត្រីស្រស់និងបន្លែ, សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់បានកើនឡើង ០,៣% ក្នុងនោះថ្លៃថ្នាំជក់កើនឡើង ០,៦%, សន្ទស្សន៍ថ្លៃដឹកជញ្ជូន កើនឡើង ១,២% ដោយសារកំណើនថ្លៃប្រេងសាំងធម្មតានិងប្រេងម៉ាស៊ូត។

បើធៀបនឹង១២ខែមុន សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈគ្មានជាតិស្រវឹងបានកើនឡើង ៦,៥%។ តាមការសង្កេតកំណើនឡើងនេះ គឺបណ្តាលមកពីឥទ្ធិពលនៃការរីកចម្រើនសេដ្ឋកិច្ចលើវិស័យសំខាន់ៗ ដូចជាវិស័យកសិកម្ម ដែលទទួលបានទិន្នផលល្អប្រសើរ វិស័យទេសចរណ៍ មានកំណើនឡើងនូវភ្ញៀវជាតិនិងអន្តរជាតិ និងវិស័យឧស្សាហកម្មក៏មានការរីកចម្រើនផងដែរ ហើយទន្ទឹមនឹងនេះបានធ្វើឱ្យមានកំណើនតម្រូវការប្រើប្រាស់ក្នុងស្រុកចំពោះម្ហូបអាហារ មានត្រី សាច់និងបន្លែជាដើម។ ផ្ទុយទៅវិញ ផលិតកម្មម្ហូបអាហារដូចជាត្រី សាច់ បន្លែ ហាក់ដូចជានៅទ្រឹងមិនឆ្លើយតបនឹងកំណើនតម្រូវការខាងលើ ធ្វើឱ្យមានការកើនឡើងថ្លៃជាប្រចាំ។

២. *ការផ្គត់ផ្គង់រូបិយវត្ថុ* គិតត្រឹមខែមករា ឆ្នាំ២០១៧ រូបិយវត្ថុទូទៅM2មានចំនួន ៥៨.៨៥២ប៊ីលានរៀល បានកើនឡើង ២,១%ធៀបនឹងខែមុន និងបានកើនឡើង ១៨,៧%ធៀបនឹង១២ខែមុន ក្នុងនោះសមាមាត្រប្រាក់រៀលមាន ១៦,៧%នៃរូបិយវត្ថុទូទៅM2 ទាបជាងខែកន្លងទៅបន្តិចដោយសារមានការថយចុះនូវប្រាក់បញ្ញើមានកាលកំណត់និងសន្សំជារៀល។

*អត្រាប្តូរប្រាក់* ប្រាក់រៀលបានឡើងថ្លៃបន្តិចធៀបនឹងខែមុនៗ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៧ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារស្មើនឹង ៤.០០៤រៀល/ដុល្លារ ដែលអត្រាខែមករា ៤.០៣៥រៀល/ដុល្លារ និងអត្រាខែធ្នូ ៤.០៣៧រៀល/ដុល្លារ។ ប្រាក់រៀលមានការប្រែប្រួលបន្តិចបន្តួចជាលក្ខណៈរដូវកាល ដោយឡើងថ្លៃជាបន្តបន្ទាប់នៅដើមឆ្នាំរហូតដល់ខែមេសា និងចាប់ផ្តើមចុះថ្លៃមកវិញបន្ទាប់ពីបុណ្យចូលឆ្នាំខ្មែរ។

*ឥណទាន* គិតត្រឹមខែមករា ឆ្នាំ២០១៧ ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ៥៨.២២៧ប៊ីលានរៀល បានកើនឡើង ២,១%ធៀបនឹងខែមុន និងបានកើនឡើង ១៦,៦%ធៀបនឹង១២ខែមុន ក្នុងនោះចំណែកនៃឥណទានផ្តល់ដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុមាន ៨២,១% ឥណទានផ្តល់ដល់គ្រឹះស្ថានហិរញ្ញវត្ថុមាន ១,៧% និងឥណទានដល់រូបវន្តបុគ្គលនិងផ្សេងៗមាន ១៦,២%។ ឥណទានផ្តល់ដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុមានចំនួន ៤៧.៨២១ប៊ីលានរៀល បានកើនឡើង ២,២%ធៀបនឹងខែមុន និងបានកើនឡើង ១៥,៤%ធៀបនឹង១២ខែមុន, ក្នុងនោះឥណទានផ្តល់ដល់វិស័យសេវាកម្មមាន ៣២.៣០៧ប៊ីលានរៀល វិស័យសំណង់ ៥.០៧៧ប៊ីលានរៀល វិស័យកសិកម្ម ៦.២៤១ប៊ីលានរៀល និងវិស័យឧស្សាហកម្ម ៤.១៩៦ប៊ីលានរៀល។

*អត្រាការប្រាក់* ក្នុងខែមករា ឆ្នាំ២០១៧ អត្រាការប្រាក់កម្ចីនៃធនាគារពាណិជ្ជសម្រាប់ប្រាក់រៀលស្មើ ១៦.២៤% និងសម្រាប់ប្រាក់ដុល្លារ ១១.៩២% ដោយមានការប្រែប្រួលតិចតួចធៀបទៅនឹងខែកន្លងទៅ, និងចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគិតត្រឹមខែធ្នូ ឆ្នាំ២០១៦កន្លងទៅ អត្រាការប្រាក់កម្ចីជាមធ្យមស្មើ ២៥%។ អត្រាការប្រាក់នេះមានកម្រិតខ្ពស់ជាងបណ្តា

ប្រទេសជាច្រើនក្នុងតំបន់, យោងតាមទិន្នន័យនៃធនាគារពិភពលោក គិតត្រឹមឆ្នាំ២០១៥ អត្រាការប្រាក់កម្ចីនៅប្រទេសថៃ ៦,៦% វៀតណាម ៧,១% ហ្វីលីពីន ៥,៦% និងមីយ៉ាន់ម៉ា ១៣,០%។ ក្នុងគោលដៅជំរុញការប្រើប្រាស់ឥណទានឱ្យមានប្រសិទ្ធភាពនិងការពារអតិថិជន នាថ្ងៃ១៣ មីនា ២០១៧ ធនាគារជាតិបានចេញសេចក្តីប្រកាសកំណត់ពិដានអត្រាការប្រាក់ឥណទានត្រឹម ១៨%។ តាមការសង្កេត ធនាគារកណ្តាលនៃប្រទេសវៀតណាមបានចាត់វិធានការ និងធ្វើឱ្យអត្រាការប្រាក់ថយចុះជាបន្តបន្ទាប់ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។

៣. ការនាំចូល÷ ក្នុងខែមករា ឆ្នាំ២០១៧ ការនាំចូលគិតជាទឹកប្រាក់មាន ១.០៨៧លានដុល្លារ បានថយចុះ ១,៨%ធៀបនឹងខែមុន ក្នុងនោះបរិក្ខារសំណង់បានកើនឡើងខ្ពស់បន្ទាប់ពីបានថយចុះក្នុងខែធ្នូកន្លងទៅ, ការនាំចូលវាយនភ័ណ្ឌបានកើនឡើងមកវិញគួរកត់សម្គាល់ គិតជាទឹកប្រាក់ខ្ពស់ជាងខែមុនៗក្នុងរយៈពេល ៨ខែចុងក្រោយនេះ, រីឯការនាំចូលគ្រឿងយន្ត ប្រេងឥន្ធនៈ និងទំនិញផ្សេងៗទៀតបានថយចុះបន្តិចធៀបនឹងខែកន្លងទៅ។ ប្រទេសដែលជាដៃគូពាណិជ្ជកម្មនាំចូលសំខាន់ៗមានប្រទេសថៃ ចិន វៀតណាម និងសិង្ហបុរីជាដើម។

ការនាំចេញ÷ ក្នុងខែមករា ឆ្នាំ២០១៧ ការនាំចេញគិតជាទឹកប្រាក់មានចំនួន ៨០៧លានដុល្លារ បានថយចុះ ១៦,២%ធៀបនឹងខែមុន ក្នុងនោះការនាំចេញកៅស៊ូបានបន្តកើនឡើង រីឯការនាំចេញប្រភេទផលិតផលវាយនភ័ណ្ឌនិងស្បែកជើង អង្ករ និងផលិតផលផ្សេងៗបានថយចុះគួរកត់សម្គាល់ធៀបនឹងខែមុន។ ប្រទេសគោលដៅនាំចេញសំខាន់ៗមានដូចជាសហរដ្ឋអាមេរិក អង់គ្លេស អាល្លឺម៉ង់ ជប៉ុន កាណាដា បារាំង និងចិន។

៤. ក្នុងឆ្នាំ២០១៦ ចំណូលក្នុងស្រុកនៃរដ្ឋបាលថ្នាក់ជាតិសុប ១៤.២០២ប៊ីលានរៀល បានកើនឡើង ១៤,៨៤%ធៀបនឹងឆ្នាំ២០១៥ ក្នុងនោះចំណូលពីអគ្គនាយកដ្ឋានពន្ធដារបានកើនឡើង ១៨,០១% និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានកើនឡើង ១៤,០១%, កំណើននេះបានបញ្ជាក់ពីប្រសិទ្ធភាពនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ជាពិសេសការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ឆ្នាំ២០១៤-២០១៨។ ចំណាយរដ្ឋបាលថ្នាក់ជាតិសុរប ១៣.៧៧៥ប៊ីលានរៀល (១៧%នៃផសស ទាបជាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ១៨,៧៥%) បានថយចុះ ៣,៧៥%ធៀបនឹងឆ្នាំ២០១៥ ដោយសារភាពប្រសើរឡើងនៃការកែលម្អនីតិវិធីចំណាយ និងការយល់កាន់តែច្បាស់របស់អ្នកអនុវត្តនីតិវិធីចំណាយនានា។ យោងតាមច្បាប់ថវិកា ២០១៧ ធៀបនឹងការអនុវត្តឆ្នាំ២០១៦ ចំណូលសុរុបថ្នាក់ជាតិកើនឡើង ១០,២% និងចំណាយសុរុបកើនឡើង ៤១,៧%។

៥. ក្នុងខែមករា ឆ្នាំ២០១៧នេះ ចំនួនគម្រោងវិនិយោគអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសុរុបមាន ៧គម្រោង បានថយចុះ៦គម្រោងធៀបនឹងខែមករា ឆ្នាំ២០១៦, សុរុបអាចបង្កើតការងារប្រមាណជាង ៣ពាន់នាក់, គិតជាទុនវិនិយោគសរុប ៣០លានដុល្លារ, ក្នុងនោះការវិនិយោគលើវិស័យកសិកម្មមានចំនួន ២៧% ឧស្សាហកម្ម ៤៧% សេវាកម្ម ១៤% និងទេសចរណ៍ ១២%។ ក្នុងឆ្នាំ២០១៦កន្លងទៅ ចំនួនគម្រោងវិនិយោគអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសុរុបមាន ១២១ គម្រោង គិតជាទុនវិនិយោគសុរប ៣.២៤៩លានដុល្លារ ក្នុងនោះវិនិយោគទុនកម្ពុជាមាន ២៩,០% និងវិនិយោគទុនពីបរទេសមានប្រទេសជប៉ុនមាន ២៣,៨% ប្រទេសចិន ២២,៥% ហុងកុង ៩,៨% បណ្តាប្រទេសតំបន់អាស៊ាន ១០,២% និងពីប្រទេសផ្សេងៗទៀត ៤,៧%។

៦. ក្នុងឆ្នាំ២០១៦កន្លងទៅ ចំនួនភ្ញៀវអន្តរជាតិបានកើនលើស ៥លាននាក់ បានកើនឡើង ៥%ធៀបនឹងឆ្នាំមុន ក្នុងនោះភ្ញៀវមកពីតំបន់អាស៊ានមាន ៤២,៣% អាស៊ីប៉ាស៊ីហ្វិក ២៩,៩% អឺរ៉ុបនិងអាមេរិក ២២,៣% និងតំបន់ដទៃទៀត

មាន ៥,៥%។ ក្នុងឆ្នាំ២០០៧ ចំនួនភ្ញៀវអន្តរជាតិមានចំនួន ២លាននាក់ និងបានកើនឡើងខ្លាំងក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ, ប៉ុន្តែកំណើននេះបានថយចុះជាបន្តបន្ទាប់គិតចាប់ពីឆ្នាំ២០១២មក។ តាមការសង្កេត ចំនួនភ្ញៀវអន្តរជាតិនៃប្រទេសជិតខាង ដូចជាថៃនិងវៀតណាមបានរក្សាកំណើនខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

៧. ក្នុងខែមករា ឆ្នាំ២០១៧ សំណើសាងសង់បានថយចុះធៀបនឹងខែធ្នូកន្លងទៅ សំណើសរុបមាន ២៩១គម្រោង គិតជាផ្ទៃក្រឡា ៣២៥ពាន់ម៉ែត្រការ៉េ និងគិតជាទឹកប្រាក់វិនិយោគសរុប ១៥៦លានដុល្លារ។ ទឹកប្រាក់និងផ្ទៃសាងសង់នៃសំណើសាងសង់មានការថយចុះក្នុងខែមករានេះ ប៉ុន្តែចំនួនសំណើសាងសង់លំនៅដ្ឋាននៅតែបន្តកើនឡើងធៀបនឹងបណ្ដាខែមុនៗ។

៨. *ថ្លៃប្រេងឆៅ* ក្នុងខែកុម្ភៈ ឆ្នាំ២០១៧ ជារួមប្រេងឆៅលើទីផ្សារអន្តរជាតិពុំមានការប្រែប្រួលគួរកត់សម្គាល់ទេធៀបនឹងខែមករាកន្លងទៅ, និងគិតចាប់ពីដើមឆ្នាំដល់ចុងខែកុម្ភៈនេះ ថ្លៃប្រេងឆៅមានការប្រែប្រួលក្នុងកម្រិតដ៏តិចតួច។ គិតត្រឹមខែកុម្ភៈនេះ ប្រេងឆៅក្នុងកិច្ចសន្យាលក់១ខែខាងមុខ ប្រេងBrentថ្លៃ ៥៥,៦ដុល្លារ/ធុង ប្រេងDubaiថ្លៃ ៥៥ដុល្លារ/ធុង និងប្រេងWITថ្លៃ ៥៤ដុល្លារ/ធុង បើធៀបនឹងខែមករាកន្លងទៅបានកើនឡើងរៀងគ្នា ០,៦%, ៤,០% និង ២,០%។ ក្នុងខែកុម្ភៈនេះ ផលិតកម្មប្រេងនិងបរិមាណប្រេងស្តុកនៃសហរដ្ឋអាមេរិកបានបន្តកើនឡើង និងបានកាត់បន្ថយឥទ្ធពលនៃការថយចុះផលិតកម្មប្រេងរបស់ប្រទេសOPECនិងប្រទេសផលិតប្រេងដ៏ទៃទៀត។

*ថ្លៃអង្ករ* នៅខែកុម្ភៈ ឆ្នាំ២០១៧ (១)អង្ករកម្ពុជានាំចេញ(ខ្ទេច៥%)ថ្លៃ ៤១៥ដុល្លារ/តោន ពុំមានការប្រែប្រួលទេធៀបនឹងខែមុន ឬ១២ខែមុន ដែលនេះគឺដោយសារការប្រឹងប្រែងរកដៃគូនាំចូលអង្ករបន្ថែមទៀតរបស់រដ្ឋាភិបាលដើម្បីទប់ស្កាត់ជាមួយការប្រកួតប្រជែងខ្លាំងនៅលើទីផ្សារក្នុងតំបន់។ (២)អង្ករថៃ នៅបាងកកអង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៣៦៩ដុល្លារ/តោន បានថយចុះ ១,៦%ធៀបនឹងខែមុន ឬបានថយចុះ ៣,៨%ធៀបនឹង១២ខែមុន។ ការថយចុះថ្លៃនេះគឺដោយសារមានការប្រជែងខ្លាំងនៅលើទីផ្សារ ក្នុងតំបន់និងពិភពលោកជាពិសេសជាមួយប្រទេសវៀតណាម និងឥណ្ឌា ហើយរដ្ឋាភិបាលថៃកំពុងព្យាយាមបញ្ចុះថ្លៃ ដើម្បីលក់ចេញអង្ករពីឃ្លាំងរបស់ខ្លួនឱ្យអស់។ (៣)អង្ករវៀតណាម អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៣៦០ដុល្លារ/តោន បានកើនឡើង ៥%ធៀបនឹងខែមុន ឬបានកើនឡើង ៤,៧%ធៀបនឹង១២ខែមុន។ កំណើនឡើងនេះគឺដោយសារការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលវៀតណាមក្នុងការនាំចេញអង្ករបន្ថែមទៀត និងមានគោលបំណងចង់ឱ្យប្រទេសចិនយល់ព្រមទទួលយកការនាំចូលអង្កររបស់ខ្លួនបន្តទៀត។

*ថ្លៃកៅស៊ូ* ក្នុងចន្លោះពាក់កណ្ដាលដើមខែកុម្ភៈ ឆ្នាំ២០១៧ ថ្លៃកៅស៊ូលើទីផ្សារអន្តរជាតិបន្តកើនឡើង ប៉ុន្តែបានថយចុះមកវិញក្នុងចន្លោះពាក់កណ្ដាលបន្ទាប់នៃខែ។ គិតត្រឹមខែកុម្ភៈ កៅស៊ូឆៅTSR20ថ្លៃ ២.១៩០ដុល្លារ/តោន បានថយចុះ ៤,៨%ធៀបនឹងខែមុន និងកើនឡើង ៩៥,៥%បើធៀបនឹង១២ខែមុន, កៅស៊ូSGP/MYSថ្លៃ ២.៤៦០ដុល្លារ/តោន បានថយចុះ ៦,១%ធៀបនឹងខែមុន និងកើនឡើង ៨៩,២%បើធៀបនឹង១២ខែមុន។ ការថយចុះនេះ មួយផ្នែកគឺដោយសារការផ្គត់ផ្គង់កៅស៊ូថៃបានត្រឡប់មករកភាពធម្មតាវិញ ដោយរាជរដ្ឋាភិបាលថៃបានដាក់លក់ចេញបន្ថែមទៀតនូវកៅស៊ូស្តុក។

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)




Source: Min. LMUC




Source: Ministry of Tourism




Source: Customs and Excise Dept.




Source: Customs and Excise Dept.




Source: MEF & Int.




Source: MEF & Int.

# អតិផរណានិងទុនបំរុងបរទេស (Inflation and Foreign Reserves)




Source: NBC




Source: NIS




Source: NIS




Source: NIS




Source: NIS




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)

**Exchange rate R/100Đ and R/B**




Source: IMF

**Exchang Rate Mal-Ringgit/$ and Phi-Peso/$**




Source: IMF

**CPI and Exchange rate R/$**




Source: IMF

**Exchange rate EU Euro/US$ and Pound/US$**




Source: IMF

**Exchange rate Aus-$ and HK-$**




Source: IMF

**Exchange rate Sing-$ and Yen-$**




Source: IMF

# វិស័យរូបិយវត្ថុ និងធនាគារ (Money and Banking)


















## ការអនុវត្តថវិការ (Budget)







Source: MEF




Source: MEF




Source: MEF




Source: MEF




Source: MEF

# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)




CDC Approval, Fixed Assets and Growth (Mn. $)

Source: CDC




CDC Approvals- Fixed Assets by Sectors (Mn. $)

Source: CDC




Number of Jobs ('000 person)

Source: CDC




Public Investment by Source of Finance (Bn.R)

Source: MEF




Net Loans Disbursement (Bn.R)

Source: MEF




CDC Approvals, Fixed assets by Sources (Mn. $)

Source: CDC

# វិស័យពាណិជ្ជកម្ម (Trades)

**Import and Export (mil.US$)**




Source: Customs and Excise Department

**Import and Export Growth**




Source: Customs and Excise Department

**Trade Balance and CA as % GDP**




Source: National Bank of Cambodia, NBC, and Customs Dept.

**Export by Main Continents (mil.US$)**




Souce: Customs and Excise Department, MEF
(including foreign currency exports )

**Export by Commodity Group ( in tonnes)**




Souce: Customs and Excise Department, MEF

**Export Clothing and Rubber (mil.US$)**




Souce: Customs and Excise Department, MEF

********

**រៀបចំដោយ**

**អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ព័ត៌មានផ្សេងៗ សូមទាក់ទង*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧៩១៣, ០៧៧ ៧០៣៤៣៦, ០៩៦ ៩៧៩១៦៨៦*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ ព្រឹក និង ២:០០ ដល់ ៥:០០ រសៀល*